ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៨៥/១១ - យ៉ុង វ៉ា

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ ម៉ារ សំបូរណា

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ លីវ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ ក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ទ្រៀល (ខេមបូឌា) ខូអិលធីឌី

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៦៧ ៥៥៥ ៩៨៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោក NG MIN CHUAN | Office Manager |
| ២- លោក វឿន លាង | Compliance Officer |

**២- ភាគីកម្មករនិយោជិត**

ក/ ឈ្មោះ ៖ - សហព័ន្ធសហជីពការងារដើម្បីកម្ពុជា

- សហជីពការងារដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន យ៉ុង វ៉ា ១

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៧ ៥១ ៥៥ ៩៥ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

១- លោក សែម សំអឿន អនុប្រធានសហព័ន្ធសហជីពការងារដើម្បីកម្ពុជា

២- លោក ហ៊ឹម សុវណ្ណ ប្រធានសហជីពការងារ ដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន

៣- លោកស្រី មុំ ស៊ីភីន អនុប្រធានសហជីពការងារ ដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន

៤- លោកស្រី ចិត ស្រីនាង លេខាសហជីពការងារ ដើម្បីកម្ពុជាប្រចាំក្រុមហ៊ុន

ខ/ ឈ្មោះ ៖ - សហព័ន្ធសហជីពកម្មករនិយោជិត

- សហជីពកម្មករនិយោជិតប្រចាំក្រុមហ៊ុន យ៉ុង វ៉ា ១

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០១២ ៩៩ ៥៥ ២៣ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

១- លោក ម៉ៃ ស៊ីម៉ា មន្ត្រីសហព័ន្ធសហជីពកម្មករនិយោជិត

២- លោកស្រី អ៊ិន សុគន្ធា អនុប្រធានសហជីពកម្មករនិយោជិត

គ/ ឈ្មោះ ៖ - សហព័ន្ធសហជីពកម្មករកម្ពុជា

- សហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន យ៉ុង វ៉ា ១

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០៧៧ ៧៧ ៦១ ៨១ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន

ឃ/ ឈ្មោះ ៖ - សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន យ៉ុង វ៉ា ១

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល

ទូរស័ព្ទ ៖ ០១៦ ២៣៥ ៤៥៨ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលបញ្ចប់កិច្ចសន្យាការងារ ដល់កម្មករនិយោជិតពេញសិទ្ធិទាំងអស់ ដែលមានអតីតភាពការងារចាប់ពីឆ្នាំ១៩៩៨ ទៅតាមច្បាប់ស្ដីពីការងារ ។ ក្រុមហ៊ុនមិនឯកភាព ។

២- កម្មករទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់៥ភាគរយ នៃប្រាក់ឈ្នួលសរុប ចាប់ពីថ្ងៃធ្វើការ រហូតដល់បច្ចុប្បន្នទៅដល់កម្មករនិយោជិតពេញសិទ្ធិទាំងអស់ ដែលមានអតីតភាពការងារពីឆ្នាំ១៩៩៨ និងរក្សាអតីតភាពការងារនៅដដែល ។ ក្រុមហ៊ុនមិនឯកភាព ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (២) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ០២៣/១១ កប/កណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងប្រជុំមុនសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទប្រជុំមុនសវនាការ ៖ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០១១ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ កម្មករនិយោជិតប្រមាណជាង១៥០០នាក់ ដឹកនាំដោយសហជីពកម្មករនិយោជិត សហជីពកម្មករកម្ពុជា សហជីពការងារដើម្បីកម្មករ និងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ បានធ្វើកូដកម្ម ដើម្បីទាមទារឱ្យក្រុមហ៊ុនកែលំអរនូវលក្ខខណ្ឌការងារមួយចំនួន២ចំណុច។ បន្ទាប់ពីបានទទួលព័ត៌មានកូដកម្មនេះភ្លាម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់មន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងារនេះ ដល់ទីតាំងរោងចក្រ ប៉ុន្តែភាគីទាំងពីរមិនបានឯកភាពសះជាទេ។ ចំណុចមិនសះជាចំនួន២ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ត្រៀល លេខ ០២៣/១១ កប/កណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ដោយសារតែការធ្វើកូដកម្មនៅតែបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០១៦/១១ កបអ. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ឱ្យផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន យ៉ុង វ៉ា អ៊ិនដាស្ត្រៀល រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកម្មករនិយោជិត ដែលធ្វើកូដកម្មទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១តទៅ តាមវេនរបស់ខ្លួន។

ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ លេខាធិការដ្ឋានក្រុមប្រឹក្សាក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមទូរស័ព្ទពីក្រុមហ៊ុនថា កម្មករនិយោជិតមិនព្រមចូលធ្វើការតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ដូចនេះ

ARBITRATION COUNCIL

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានឱ្យលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលកោះអញ្ជើញភាគីកម្មករនិយោជិត និងក្រុមហ៊ុនមកចូលរួមកិច្ចប្រជុំមុនសវនាការ ដើម្បីសាកសួរព័ត៌មានស្តីពីកូដកម្ម នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។ ក្នុងកិច្ចប្រជុំមុនសវនាការនេះ ជាបឋម ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពន្យល់ប្រាប់ភាគីទាំងពីរអំពីនីតិវិធីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល និងស្នើឱ្យភាគីទាំងពីររក្សាភាពស្ងប់ស្ងាត់ ចៀសវាងការធ្វើវិវាទឱ្យកាន់តែធ្ងន់ធ្ងរ។ មានន័យថាកម្មករនិយោជិតត្រូវបញ្ឈប់ការធ្វើកូដកម្ម។ ជាដំបូងសហជីព ការងារដើម្បីកម្មករ និងសហជីពកម្មករនិយោជិតដែលមានវត្តមាននៅក្នុងកិច្ចប្រជុំមុនសវនាការ បញ្ជាក់ថា មកដល់ពេលនេះ កម្មករនិយោជិតមិនព្រមស្តាប់តាមការពន្យល់របស់សហជីពនោះទេ គឺពួកគាត់ ជ្រើសរើសដើម្បីបន្តកូដកម្ម។ ហេតុនេះ សហជីពទាំងពីរសុំដកសិទ្ធិជាតំណាងរបស់កម្មករនិយោជិត ដែលជាសមាជិករបស់ខ្លួនចេញ។ ចំពោះសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរបានផ្ញើរលិខិតដកពាក្យបណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈលិខិតចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១។ ចំពោះសហជីពកម្មករកម្ពុជាបានបញ្ជាក់មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈទូរស័ព្ទថា មិនចូលរួមដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ មកដល់ថ្ងៃប្រជុំនេះ សហជីពចំនួនបីនេះ មិនតំណាងឱ្យកម្មករនិយោជិតដែលធ្វើកូដកម្មទៀតឡើយ។ តាមរយៈនិយោជក និងសហជីព មកដល់ពេលនេះ កម្មករនិយោជិតនៅតែប្រកាន់ជំហរធ្វើកូដកម្ម។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

- លិខិតដកពាក្យបណ្តឹងរបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ២០១១។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យ៉ុង វ៉ា លេខ ០២៣/១១ កប/កណ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន យ៉ុង វ៉ា ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៩៦០ កប/អក/វក/លក្រអ. ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមកិច្ចប្រជុំមុនសវនាការលេខ ៩៦១ កប/អក/វក/លកអ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១១ ។

**អង្គហេតុ**

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការសវនាការបាន។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម*"។

យោងតាមប្រការ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា*កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទ កាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល*។

នៅក្នុងសេចក្តីបញ្ជាមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករកំពុងធ្វើកូដកម្ម។

ឧទាហរណ៍ នៅក្នុងសំណុំរឿងសេចក្តីបង្គាប់លេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ ចែងថា ៖

"*ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម*"។

ដូចគ្នាដែរ នៅក្នុងរឿងក្តី ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែន្ទ ឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និង សូភីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

"*ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ*"។

*" ចំណុចទី១១- ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ " ។*

នៅក្នុងសំណុំរឿង ៧៧/០៦-ប្រ៊្លង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ២៨/០៦-ជី ឌី អឹម ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់បិទសំណុំរឿងនោះចោល ដោយមូលហេតុកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងកំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

ផ្អែកលើការបកស្រាយខាងលើ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនព្រមគោរពតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ពោលគឺពុំបានបង្ហាញពីចេតនាពិតប្រាកដណាមួយថា ភាគីកម្មករនិយោជិតមានបំណងយកវិវាទការងាររួមនេះ មកដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ។

ដូច្នេះ ដោយផ្អែកតាមប្រការ ២០ នៃប្រកាស ០៩៩ និងដើម្បីឱ្យស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗពាក់ព័ន្ធនឹងករណីកូដកម្ម ដូចដែលមានចែងក្នុងប្រការ២០ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះទេ ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ ៖

## សម្រេច និង បង្គាប់

- មិនបន្តដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ១៨៥/១១ - យ៉ុង វ៉ា នេះទេ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ----------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីម សុវណ្ណា**

ហត្ថលេខា: ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា: ----------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL